**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៥៥២ អនក្រ.តត**

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកកំពង់លែង នៃខេត្តកំពង់ឆ្នាំង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ១៣៧ គជប.សសរ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០០៩ ស្តីពីបេក្ខជនជាប់ឆ្នោតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកកំពង់លែង នៃខេត្តកំពង់ឆ្នាំង អាណត្តិទី១ ដូចមានរាយនាមខាងក្រោម :

១- លោក **ឡោ សាលីម** ជាប្រធានក្រុមប្រឹក្សាស្រុក

២- លោកស្រី ថ្រាំ ធីតា ជាសមាជិកក្រុមប្រឹក្សាស្រុក
៣- លោក អ៊ុន សារូ ជាសមាជិកក្រុមប្រឹក្សាស្រុក
៤- លោក ឆេង សារឿន ជាសមាជិកក្រុមប្រឹក្សាស្រុក
៥- លោក គង់ គន ជាសមាជិកក្រុមប្រឹក្សាស្រុក
៦- លោក ជិន ចេង ជាសមាជិកក្រុមប្រឹក្សាស្រុក
៧- លោក ខៀវ សារៀម ជាសមាជិកក្រុមប្រឹក្សាស្រុក
៨- លោក មាឃ ស៊ីថន ជាសមាជិកក្រុមប្រឹក្សាស្រុក
៩- លោកស្រី មុត សុមាលី ជាសមាជិកក្រុមប្រឹក្សាស្រុក
១០- លោក សុខ គាន ជាសមាជិកក្រុមប្រឹក្សាស្រុក
១១- លោក មុំ ម៉ុល ជាសមាជិកក្រុមប្រឹក្សាស្រុក
១២- លោក សួន សាគុណ ជាសមាជិកក្រុមប្រឹក្សាស្រុក
១៣- លោក ហួត ស៊ីម ជាសមាជិកក្រុមប្រឹក្សាស្រុក
១៤- លោក ជូ សំអុន ជាសមាជិកក្រុមប្រឹក្សាស្រុក
១៥- លោក ញឹក សំអឿល ជាសមាជិកក្រុមប្រឹក្សាស្រុក

**មាត្រា ២ :** ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់ បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ២២ និងមាត្រា២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៣ :** ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាស្រុកកំពង់លែង នៃខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

__កន្លែងទទួល :__
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*

*(__ដើម្បីជូនជ្រាប__)*
- *ដូចមាត្រា ៥*
- *ឯកសារ កាលប្បវត្តិ*